# ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា

**THE MINNESOTA CAMBODIAN BUDDHIST SOCIETY; INC. WATT MUNISOTARAM**

**A NON-PROFIT RELIGIOUS INCORPORATION**

2925 220th Street East, Hampton, MN 55031 Tel: (651) 463-3101 http://www.wattmunisota.org


# បុណ្យព្រះសារីរិកធាតុ – បុណ្យបញ្ចុះបឋមសិលា
# បុណ្យខួបវត្ត – បុណ្យផ្កាសាមគ្គីកសាងព្រះសក្យមុនីចេតិយ

ខ្ញុំព្រះករុណា អាត្មាភាព យើងខ្ញុំជាព្រះសង្ឃ ក្រុមអភិបាលវត្ត និងពុទ្ធបរិស័ទនៃពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា មានបីតិសោមនស្ស ជ្រះថ្លាប្រារព្ធធ្វើបុណ្យព្រះសារីរិកធាតុនៃព្រះសក្យមុនីសម្ពុទ្ធ នឹងព្រះធាតុនៃព្រះអរហន្តជាអគ្គសាវ័ក ដែលនិមន្តនាំមកដោយមន្ត្រីសង្ឃជាតិសិរីលង្កា ដែលមានព្រះតេជគុណ សីវលីថេរោ ប្រធានសង្ឃនៃសមាគមមហាពោធិ នៅពុទ្ធគយា ប្រទេសឥណ្ឌា, ព្រះតេជគុណ ជិនរតនថេរោ នៅប្រទេស សិរីលង្កា បានថ្វាយព្រះសារីរិកធាតុមកពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា ។

ការថ្វាយនូវព្រះសារីរិកធាតុនេះ ដូចជាព្រះភគវន្តមុនីសាស្តា យាងមកប្រតិស្ឋានក្នុងរដ្ឋមិនីសូតា សហរដ្ឋអាមេរិក ដើម្បីជាទីគោរពបូជានៃពុទ្ធបរិស័ទទាំងឡាយគ្រប់មជ្ឈដ្ឋាន និងជាតិសាសន៍នានា ដែលជាមហាភ័ព្វសំណាងបានគោរពបូជា រមែងទទួលនូវផលានិសង្សជាច្រើនអនេកប្បការ នឹងនាំឱ្យយើងរំលឹកដល់ប្រវត្តិ និងគុណធម៌របស់ព្រះពុទ្ធទាំងឡាយ មានករុណាគុណ វិសុទ្ធិគុណ និងបញ្ញាគុណ ហើយព្រះអង្គបានបង្ហាញមាគ៌ាមជ្ឈិមាបដិបទាឱ្យយើងដើរតាម ដើម្បីឱ្យសត្វលោកបាននូវសុភមង្គល សន្តិភាព នឹងរំលត់នូវទុក្ខក្នុងវាលវដ្តសង្សាររហូតដល់ព្រះនិព្វានជាទីអវសាន្ត ។

ក្នុងឱកាសបុណ្យព្រះសារីរិកធាតុ ខ្ញុំព្រះករុណា យើងខ្ញុំ នឹងប្រារព្ធនូវបុណ្យបញ្ចុះបឋមសិលា ជាគោលចារឹកនៃកិច្ចចាប់ផ្តើមកសាងព្រះសក្យមុនីចេតិយ ជាបូជនីយដ្ឋានដំកល់ព្រះសារីរិកធាតុ ព្រះពុទ្ធរូបបរិនិព្វាន ស្នាមព្រះបាទនៃព្រះសម្ពុទ្ធ និងព្រះពុទ្ធរូប២៨អង្គផង ភ្ជាប់នឹងថ្ងៃនោះដែរ មានធ្វើបុណ្យខួបវត្តមុនីសុតារាម ឆ្នាំទី២១ និងបុណ្យផ្កាសាមគ្គី ដើម្បីបានបច្ច័យឧបត្ថម្ភកសាងព្រះសក្យមុនីចេតិយ ជាទីគោរពបូជានៃព្រះសង្ឃ ពុទ្ធបរិស័ទ និងជាតិសាសន៍នានាគ្រប់ទិសទី ។

សូមព្រះថេរានុត្ថេរៈ លោក លោកស្រី ពុទ្ធបរិស័ទទាំងឡាយ មេត្តាជួយចាប់កុសល និងអនុមោទនាទទួលនូវផលានិសង្សនៃបុណ្យ ព្រះសារីរិកធាតុ បុណ្យបញ្ចុះបឋមសិលា បុណ្យផ្កាសាមគ្គី និងបុណ្យខួបវត្តមុនីសុតារាម ដោយសទ្ធាជ្រះថ្លា និងសោមនស្សរីករាយ ។

## <u>កាលបរិច្ឆេទបុណ្យ</u>

-ថ្ងៃសុក្រ ៨រោច ខែ ស្រាពណ៍ ព.ស. ២៥៥៣ ត្រូវនិងថ្ងៃទី ១៤ ខែ សីហា គ.ស. ២០០៩

វេលាម៉ោង ៩:៣០ ព្រឹក : នមស្សការព្រះរតនត្រ័យ សមាទានសីល រាប់បាត្រ ដារបង្សុកូល

វេលាម៉ោង ១១:០០ ព្រឹក : វេរចង្ហាន់ចំពោះព្រះសង្ឃ និងភត្តានុមោទនា

-វេលាម៉ោង ៧:០០ ល្ងាច : ព្រះសង្ឃ ពុទ្ធបរិស័ទកាន់គ្រឿងសក្ការបូជា ធ្វើវន្ទនកិច្ចប្រទក្សិណ បីជុំព្រះសារីរិកធាតុនិងព្រះពុទ្ធរូប ព្រមទាំងសូត្រព្រះបារមី៣០

: សូត្របទថ្វាយផ្កា នមស្សការ សុំសីល ព្រះសង្ឃសូត្រមន្ត

: ថ្លែងបុព្វហេតុបុណ្យ និងព្រះសង្ឃសិរីលង្កាធ្វើសង្ហថាប្រគល់ព្រះសារីរិកធាតុ ដល់ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម និងចៅអធិការវត្តថ្លែងសោមនស្សកថា

: ធម្មទេសនា អំពីមហាសតិបដ្ឋាន

: ព្រះសង្ឃសូត្រធម៌ប្រសិទ្ធីលើកព្រះសារីរិកធាតុដាក់លើសិរសានៃពុទ្ធបរិស័ទ

-ថ្ងៃសៅរ៍ ៩រោច ខែ ស្រាពណ៍ ព.ស. ២៥៥៣ ត្រូវនិងថ្ងៃទី ១៥ ខែ សីហា គ.ស. ២០០៩

វេលាម៉ោង ៩:០០ ព្រឹក : នមស្សការព្រះរតនត្រៃ ព្រះសង្ឃ ពុទ្ធបរិស័ទ ភ្ញៀវជនជាតិនានា ចូលថ្វាយបង្គំ និងទស្សនាព្រះសារីរិកធាតុ ព្រមទាំងស្រង់សុគន្ធវារីព្រះពុទ្ធរូប

វេលាម៉ោង ១០:១៥ ព្រឹក : ព្រះសង្ឃជាច្រើនអង្គនិមន្តបិណ្ឌបាត្រ

វេលាម៉ោង ១១:០០ ព្រឹក : វេរចង្ហាន់ចំពោះព្រះសង្ឃ និងភត្តានុមោទនា

វេលាម៉ោង ១:០០ រសៀល: ពុទ្ធបរិស័ទ ភ្ញៀវជនជាតិនានា ចូលថ្វាយបង្គំនិងទស្សនាព្រះសារីរិកធាតុ ដោយមានពិធីសូត្រធម៌ប្រសិទ្ធីពីព្រះសង្ឃផង

វេលាម៉ោង ៦:០០ ល្ងាច : ពិធីគោរពទង់ និងដង្ហែព្រះសារីរិកធាតុ គម្ពីរព្រះត្រៃបិដកក្នុងបរិវេណវត្ត

: ក្បួនដង្ហែមាន ក្រុមឆៃយ៉ាំ ភ្លេងពិណពាទ្យ រថបុស្សបុកដំកល់ព្រះសារីរិកធាតុ ដោយព្រះសង្ឃ ក្រុមអភិបាល ពុទ្ធបរិស័ទ និងជាតិសាសន៍នានា

: របាំថ្វាយផ្កា និងថ្វាយទៀន

: នមស្សការព្រះរតនត្រៃ សមាទានសីល

: តំណាងព្រះសង្ឃនិងពុទ្ធសាសនិកជាតិនានាសូត្រធម៌ និងថ្លែងចំណាប់ អារម្មណ៍អំពីសារីរិធាតុនៃព្រះសម្មាសម្ពុទ្ធ និងព្រះសាវ័កទាំងឡាយ

: ធម្មទេសនា អំពីធម្មចក្កប្បវត្តនសូត្រ

-ថ្ងៃអាទិត្យ ១០រោច ខែ ស្រាពណ៍ ព.ស. ២៥៥៣ ត្រូវនិងថ្ងៃទី ១៦ ខែ សីហា គ.ស. ២០០៩

វេលាម៉ោង ៩:០០ ព្រឹក : ពិធីបុណ្យបញ្ចុះបឋមសិលា ដើម្បីសាងសង់ព្រះសក្យមុនីចេតិយ

វេលាម៉ោង ១១:០ ព្រឹក : វេរចង្ហាន់ចំពោះព្រះសង្ឃ និងភត្តានុមោទនា

វេលាម៉ោង ១:០០ រសៀល: ដង្ហែផ្កាសាមគ្គី កសាងព្រះសក្យមុនីចេតិយ នៅវត្តមុនីសុតារាម

វេលាម៉ោង ៥:០០ ល្ងាច : ធម្មទេសនា អំពីបដិច្ចសមុប្បាទធម៌

វេលាម៉ោង ៧:០០ ល្ងាច : ឆ្លងពិធីបុណ្យនិងយាងព្រះសារីរិកធាតុដំកល់នៅព្រះវិហារជាន់ខាងលើ។

ពុទ្ធិកសមាគមខ្មែរ វត្តមុនីសុតារាម រដ្ឋមិនីសូតា

THE MINNESOTA CAMBODIAN BUDDHIST SOCIETY; INC.

A NON-PROFIT RELIGIOUS INCORPORATION

2925 220th Street East, Hampton, MN 55031 Phone: (651) 463-3101

www.wattmunisota.org E-mail: mcbs_munisotaram@yahoo.com

**Veneration of the relics of the Buddha – Ground Breaking for the stupa – MCBS' s anniversary – Flower-festival for the construction of the stupa.**

We, members of the Sangha, MCBS's board and Cambodian Buddhist community at Watt Munisotaram in Minnesota, with deep joy and purity of our mind, are planning a memorial celebration to honor the relics of the Buddha which will be brought from Sri Lanka to Watt Munisotaram by a distinguished group of Sri Lanka official Buddhist monks including Venerable P. Seewalee Thero of the Maha Bodi Society of India and Venerable Jinarathana of Sri Lanka, who had given us valuable assistance and help.

The relics of the Buddha, which will be enshrined at Watt Munisotaram, will make Minnesota the one of states in the United States to be a privileged place where people of different races and faiths are fortunate to be permanently blessed by the presence of the Buddha - the proof of perfect enlightenment, the symbol of perfect wisdom, love and compassion. The presence of the relics of the Buddha will also serve as a permanent reminder to all of us that the path to complete liberation, happiness and peace is possible through our own determined personal effort.

This memorial celebration will also mark the day of the ground breaking for the construction of the stupa where the relics of the Buddha will be enshrined, the 21st celebration of the MCBS's anniversary, and the Flower festival to support the construction of the stupa.

We therefore ask all the participants to actively support this three-day event and enjoy the merit that will flow from their good deeds.

## Schedule

**Friday, August 14, 2009**

9:30 A.M.

Paying respect to the Triple Gem; taking the Five Precepts; offering alms for our spiritual benefits and for the spiritual benefits of our parents and ancestors.

11:00 A.M. Offering lunch to Buddhist monks and receiving their blessings.

From 7:00 P.M. Successive activities as follows:

- Members of the Buddhist community led by the Buddhist monks circumambulate the relics of the Buddha and the Buddha images 3 times and chant the 30 perfection of the Buddha
- Chanting the flower-offering verse; paying respect to the Triple Gem; taking the Five Precepts; chanting the Dhamma
- Welcome speech; speech by Sri Lanka Buddhist monks formally offering the relics of the Buddha to Watt Munisotaram; speech by the abbot of Watt Munisotaram accepting and thanking for the sacred gift.
- Dhamma talk about Satipatthana Sutra (Discourse on The Four Foundations of Mindfulness)
- Blessing session – members of the community take turn to receive blessing from the Buddhist monks by placing the relics of the Buddha on their head

**Saturday, August 15, 2009**

9:00 A.M.

Paying respect to the Triple Gem; veneration of the relics of the Buddha by Buddhist monks, members of the Buddhist community and guests; receiving grace by washing the Buddha statues with scented water

10:15 A.M.

Buddhist monks conveying merit to community members by going for alms-food

11:00 A.M.

Offering lunch to Buddhist monks and receiving their blessings.

1:00 P.M.

Veneration of the relics of the Buddha by the members of the community and guests and special blessings from the Buddhist monks

From 6:00 P.M.  Successive activities as follows:

- Salute Buddhist flag; parade led by Chhayam band and Pinpeard band within Watt Munisotaram monastery involving Buddhist monks, members of the community and guests carrying the relics of the Buddha and the three Great Collections of Books called “Tipitaka”
- Flower-and-candle offering dance
- Paying respect to the Triple Gem; taking the Five Precepts
- Chanting by Buddhist monks representing various Buddhist communities to honor the relics of the Buddha and the relics of the Buddha’s disciples and Dhamma talk about the “Four Noble Truths” – doctrine which is profound and sublime.

**Sunday, August 16, 2009**

9:00 A.M.

Ground Breaking for the stupa

11:00 A.M.

Offering lunch to Buddhist monks and receiving their blessings.

1:00 P.M.

Flower-festival parade and ritual and veneration of the relics of the Buddha by the members of the community and guests and special blessings from the Buddhist monks

5:00 P.M.

Dhamma talk about Paticchasamuppada [Dependent Origination]

7:00 P.M.

Closing ceremony religiously placing the relics of the Buddha on the upper level of the temple.